# មេរៀនទី ១៣១៖ ដាវីឌក្លាយទៅជាស្តេច

## ២សាំយូអែល ៥៖១-៥ ទំនុកតម្កើង៣៧

**មេរៀនសម្រាប់កុមារ** ( *យូធូបលីង* )៖ https://youtu.be/Mafj6_c1oio

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/HAYzloNEnzs

**គោលបំណង៖ ព្រះគួរជាទីទុកចិត្ត។**

**ខគម្ពីរចងចាំ៖ សុភាសិត ៣៖៥-៦** *"ចូរទីពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ ត្រូវឲ្យទទួលស្គាល់ទ្រង់នៅគ្រប់ទាំងផ្លូវឯងចុះ នោះទ្រង់នឹងដំរង់អស់ទាំងផ្លូវច្រករបស់ឯង។"*

**ចំរៀង** ( *យូធូបលីង* )៖

១. ស្តេចលើស្តេច https://youtu.be/CPBqHYVwm3M
២. បើអ្នកសប្បាយក្នុងព្រះយេស៊ូវ https://youtu.be/SsldqdQB-9U
៣. ខ្ញុំនឹងទុកចិត្ត ទ្រង់ https://youtu.be/WCZlwlstAzc

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «គួរឲ្យទុកចិត្ត ឬក៏មិនគួរឲ្យទុកចិត្ត»

សម្ភារៈដែលត្រូវការ៖ ដបទឹក២ដូចគ្នា(ដបមួយចោះរន្ធតូចមួយនៅផ្នែកខាងក្រោម) អាវភ្លៀង២ដូចគ្នា (ប៉ុន្តែមួយគឺរហែក) ប៊ិក២ដូចគ្នា (តែមួយប្រើមិនកើត) អ្វីមួយក៏បានដែលមួយអាចប្រើបាន ហើយមួយទៀតមិនអាចប្រើបាន



១. ចែកកុមារជា២ក្រុម
២. ដាក់ដបទឹកទាំង២នៅចុងម្ខាងនៃថ្នាក់រៀន
៣. អ្នកស្ម័គ្រចិត្តមកពីក្រុមទាំងពីរត្រូវរត់ទៅឯចុងម្ខាងនៃថ្នាក់រៀន ហើយយកដបទឹកមួយរួចរត់ត្រឡប់មករកគ្រូវិញ
៤. គ្រូនឹងពិនិត្យមើលដបទឹក ក្រុមណាដែលយកដបទឹកដែលគ្មានរន្ធមកឲ្យគ្រូនឹងទទួលបាន១ពិន្ទុ





៥. លេងល្បែងនេះសារឡើងវិញ ដោយប្រើអាវភ្លៀង ប៊ិក និងរបស់របរផ្សេងទៀតដែលមួយប្រើកើត ហើយមួយទៀតប្រើមិនកើត
៦. គ្រូអាចឲ្យសិស្សលេងល្បែងនេះម្តងទៀតបាន ដោយប្រើសម្ភារៈ ដដែល
៧. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា សម្ភារៈទាំងអស់គឺមើលទៅដូចគ្នាបិះបិទ ប៉ុន្តែមួយប្រើកើត មួយទៀតប្រើមិនកើត។ ក្នុងនាមជាគ្រិស្តបរិស័ទ យើងតែងតែអាចទុកចិត្តលើព្រះបាន ដោយសារព្រះមានឫទ្ធានុភាព ហើយទ្រង់មិនដែលប្រែប្រួលឡើយ។

### ៤. ការណែនាំមេរៀន

តើអ្នកធ្លាប់ជិះឡានដែរឬទេ? នៅពេលដែលអ្នកជិះឡាន អ្នកបានផ្ញើជីវិតលើអ្នកបើកឡាន។ តើអ្នកទុក

ចិត្តលើអ្នកបើកដែរឬទេ? តើអ្នកទុកចិត្តលើនរណានៅក្នុងជីវិតរបស់អ្នក? តើអ្នកអាចពឹងផ្អែកលើឪពុកម្ដាយរបស់អ្នកបានដែរឬទេ? តើអ្នកអាចពឹងផ្អែកលើមិត្តរបស់អ្នកបានដែរឬទេ? តើអ្នកអាចពឹងផ្អែកលើមិត្តដែលតែងតែនិយាយកុហកបានដែរឬទេ? តើអ្នកអាចពឹងផ្អែកលើមនុស្ស ដែលអ្នកមិនស្គាល់បានដែរឬទេ? ថ្ងៃនេះយើងនឹងរៀនថា យើងអាចពឹងផ្អែកលើព្រះជានិច្ច ពីព្រោះព្រះតែងតែល្អមានប្រាជ្ញា និងសេចក្ដីស្រឡាញ់ ហើយតែងតែធ្វើតាមការសន្យារបស់ទ្រង់។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

កាលពីកុមារភាពដាវីឌគឺជាអ្នកគង្វាលចៀម។ ព្រះគម្ពីរបាននិយាយថា គាត់បានមើលថែ និងការពារសត្វចៀមបានយ៉ាងល្អ។ ដាវីឌបានពឹងផ្អែកលើព្រះក្នុងការជួយគាត់មើលថែចៀមទាំងអស់នោះ។ ព្រះបានផ្ដល់ឲ្យគាត់នូវកម្លាំង និងប្រាជ្ញា។ ព្រះគម្ពីរបានប្រាប់យើងថា ដាវីឌបានធំធាត់ឡើងដើម្បីធ្វើជាអ្នកចម្បាំង។ គាត់បានបម្រើនៅក្នុងជួរកងទ័ព។ គាត់គឺជាទាហានដ៏ក្លាហាន។ គាត់បានប្រយុទ្ធជាមួយនឹងយក្សកូលីយ៉ាតដ៏ធំ ដោយគ្រាន់តែប្រើខ្សែ និងថ្មប៉ុណ្ណោះ។ ពេលខ្លះគាត់បានប្រយុទ្ធដោយប្រើធ្នូ និងព្រួញ។

ដាវីឌគឺជាអ្នកចម្បាំងដ៏ជោគជ័យម្នាក់ដោយសារគាត់ពឹងផ្អែកលើព្រះ។ ដាវីឌបានដឹងថាគាត់អាចទុកចិត្តព្រះ ដើម្បីជួយគាត់ឲ្យក្លាយជាអ្នកចម្បាំងដ៏ក្លាហាន។ សូម្បីតែពេលស្ដេចសូលព្យាយាមសម្លាប់គាត់ដោយសារការច្រណែន ក៏ដាវីឌបានពឹងផ្អែកលើព្រះដើម្បីការពារគាត់ដែរ។

ថ្ងៃមួយ ស្ដេចសូលក៏បានសោយទិវង្គតនៅក្នុងសមរភូមិ។ កូនចៅរបស់ស្ដេចសូលទាំងអស់ក៏ស្លាប់ក្នុងសមរភូមិដែរ។ ដូច្នេះ ដាវីឌក៏បានក្លាយជាស្ដេចបន្ទាប់របស់សាសន៍អ៊ីស្រាអែល។ ដាវីឌត្រូវដឹកនាំប្រជាជនដោយប្រាជ្ញា។ គាត់ត្រូវតែបង្កើតច្បាប់ឲ្យបានល្អសម្រាប់ប្រជាជន។ ដាវីឌត្រូវធ្វើការសម្រេចចិត្តឱ្យបានល្អ ពីអ្វីដែលល្អបំផុតសម្រាប់ប្រទេសរបស់គាត់។

ដាវីឌបានពឹងលើព្រះដើម្បីជួយគាត់ឲ្យក្លាយជាស្ដេចដ៏ល្អ។ គាត់បានដឹងថាគ្មានអ្នកណាដែលគាត់អាចទុកចិត្តបានក្រៅពីព្រះនោះទេ។ ស្ដេចដាវីឌដឹងថាព្រះគួរឲ្យទុកចិត្ត និងអាចពឹងពាក់បាន។

នៅពេលដែលយើងនិយាយថាព្រះជាម្ចាស់អាចពឹងពាក់បាន នោះមានន័យថាទ្រង់រឹងមាំ ព្រះអង្គគួរឱ្យទុកចិត្ត ព្រះជាម្ចាស់នឹងជួយយើងជានិច្ច ហើយទ្រង់តែងតែល្អជានិច្ច។ ទ្រង់មានប្រាជ្ញា តែងតែស្រឡាញ់ ហើយព្រះអង្គនឹងថែរក្សាយើងជានិច្ចផងដែរ។

យើងអាចពឹងផ្អែកលើព្រះឲ្យជួយយើង ទោះបីជាយើងភ័យខ្លាចក៏ដោយ។ ពេលខ្លះព្រះជួយយើងដោយផ្ដល់ភាពក្លាហានដល់យើង។ ជួនកាលព្រះជួយយើងដោយបញ្ជូនមនុស្សម្នាក់មកជួយដល់យើង។ ជួនកាលព្រះជួយយើងឱ្យដឹងពីរបៀបធ្វើអ្វីមួយ។

យើងអាចទុកចិត្តព្រះក្នុងការណែនាំយើង — ដើម្បីបង្ហាញយើងពីផ្លូវត្រឹមត្រូវ — ដោយសារ ព្រះជាទីទុកចិត្ត។ ចូរយើងធ្វើដូចស្ដេចដាវីឌ ហើយពឹងផ្អែកលើព្រះដែលគួរជាទីទុកចិត្ត!

## ៦. សំនួរពិភាក្សា

១. តើនរណាដែលបានជួយដាវីឌឲ្យក្លាយជាអ្នកគង្វាលចៀមដ៏ល្អ? *(ព្រះ)*

២. តើនរណាដែលបានជួយដាវីឌឲ្យក្លាយជាអ្នកចម្បាំងដ៏ក្លាហាន? *(ព្រះ)*

៣. តើនរណាដែលបានជួយដាវីឌឲ្យក្លាយជាស្ដេចដ៏ល្អ ?*(ព្រះ)*

៤. តើដាវីឌពឹងពាក់លើនរណាក្នុងជីវិតរបស់គាត់? *(ព្រះ)*

៥. តើអ្នកអាចពឹងពាក់លើនរណាដើម្បីជួយអ្នកគ្រប់ផ្លូវទាំងអស់នៃដំណើរជីវិតរបស់អ្នក? *(ព្រះ)*

**៧. ល្បែងកំសាន្ត** «ស្តេចបញ្ជា»



១.ឲ្យកុមារឈរជាជួរ ហើយប្រុងប្រយ័ត្នក្នុងការស្តាប់គ្រូ

២.ប្រសិនបើគ្រូនិយាយថា“ស្តេចបញ្ជាឲ្យ..” កុមារទាំងអស់ត្រូវតែធ្វើតាម

៣.ប៉ុន្តែប្រសិនបើគ្រូមិនបាននិយាយពាក្យថា“ស្តេចបញ្ជា...”នោះកុមារមិន ត្រូវធ្វើតាមគ្រូនោះទេ។

៤.ឧទាហរណ៍៖ ប្រសិនបើគ្រូនិយាយថា “ស្តេចបញ្ជាឲ្យ ទះដៃ” ដូច្នេះកុមារទាំងអស់ត្រូវតែទះដៃ។

៥.បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ស្តេចមានអំណាចក្នុងការបញ្ជាឲ្យមនុស្សធ្វើអ្វីក៏បាន។ យើងគួរតែមានភាពសប្បាយរីករាយ ពីព្រោះព្រះដែលជាស្តេចរបស់ យើង ដែលអាចឲ្យយើងទុកចិត្តបាន ហើយបញ្ជាឲ្យយើងធ្វើនូវអ្វីដែលល្អត្រឹមត្រូវសម្រាប់ខ្លួនយើង។

**៨. ខគម្ពីរចងចាំ**

**សុភាសិត ៣៖៥-៦** *“ចូរទីពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ ត្រូវឲ្យទទួលស្គាល់ទ្រង់នៅគ្រប់ទាំងផ្លូវឯងចុះ នោះទ្រង់នឹងដំរង់អស់ទាំងផ្លូវច្រករបស់ឯង។”*

**៩. ហត្ថកម្ម** **«ព្រះជាម្ចាស់ប្រៀបបាននឹងឆ័ត្រឥន្ទ»**

សម្ភារៈដែលត្រូវការ៖ ចានក្រដាស កន្ត្រៃ កូល័រ កាវបិត និងក្រដាស




១. ឲ្យចានក្រដាសដែលបានកាត់ជាពីររួចទៅកុមារម្នាក់មួយ

២.ឲ្យកុមារតុបតែងចានក្រដាសនោះ ហើយសរសេរពាក្យថា “ព្រះជាម្ចាស់ជាទីទុកចិត្ត”នៅចំកណ្តាល។

*(សម្រាប់កុមារមួយចំនួនគ្រូអាចសរសេរជំនួសបាន)*

៣.ឲ្យកុមារកាត់ដងឆត្រ័ចេញមក ហើយបិតវាភ្ជាប់ជាមួយចានក្រដាស។

៤. (ជម្រើស) ប្រសិនបើកុមារចង់បាន ពួកគេអាចបង្កើតតំណក់ទឹកភ្លៀងដោយ កាត់ក្រដាសស្តើងមួយ ហើយបិតរង្វង់ដើម្បីភ្ជាប់ទៅនឹងឆ័ត្រ។

៥. សូមពន្យល់កុមារថា យើងតែងតែអាចពឹងផ្អែកលើព្រះដើម្បីជួយយើង និងការពារយើង សូម្បីតែពេលមានព្យុះ ភ្លៀងនៅក្នុងជីវិតរបស់យើងក៏ដោយ។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
តាមរយៈព្រះយេស៊ូវ ព្រះបានបង្ហាញយើងពីរបៀបដែលយើងអាច ពឹងផ្អែកលើទ្រង់គ្រប់ជំហាននៃជីវិតរបស់យើង។ ដោយសារភាពក្លាហានរបស់ព្រះយេស៊ូវ យើងអាចជឿថាការទុកចិត្តលើព្រះនឹងមានតម្លៃជានិច្ច! តើព្រះ ប្រើអ្វីដើម្បីបង្រៀនអ្នកឥឡូវនេះអំពីការពឹងផ្អែកលើទ្រង់? សុំប្រាជ្ញាពីព្រះដើម្បីមើលឃើញ និងមានកម្លាំង ដើម្បីឈានទៅមុខដោយសេចក្តីជំនឿ។ អ្នកអាចពឹងផ្អែកលើព្រះ ពីព្រោះទ្រង់មានអ្វីគ្រប់យ៉ាង ដែលអ្នកត្រូវការជានិច្ច។